ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤១ សសរ

សេចក្តីសម្រេច
ស្តីពី
ការកែសម្រួលសមាសភាពក្រុមការងារដើម្បីរៀបចំ សម្របសម្រួល និងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទតាមវិធីសាស្ត្រ «ចលនាភូមិថ្មី»

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ៥១ អនក្រ.បក ចុះថ្ងៃទី២១ ខែ មិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងសេចក្តីសម្រេចលេខ៥៧ សសរ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៤ ស្តីពីការបង្កើតក្រុមការងារដើម្បីរៀបចំ សម្របសម្រួល និងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទតាមវិធីសាស្ត្រ «ចលនាភូមិថ្មី»
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

សម្រេច

ប្រការ ១.-

ត្រូវបានកែសម្រួលសមាសភាពក្រុមការងារដើម្បីរៀបចំ សម្របសម្រួល និងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទតាមវិធីសាស្ត្រ "ចលនាភូមិថ្មី" ដែលមានសមាសភាពដូចខាងក្រោម ៖

១. ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ប្រធាន

www.pheakdeylaw.com

២. ឯកឧត្តម **អ៊ូ សំអួន**	រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ	អនុប្រធាន
៣. ឯកឧត្តម **ខាំ សណ្ដាប់**	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	អនុប្រធាន
៤. ឯកឧត្តម **ស្មាន ម៉ាណាន**	អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
៥. ឯកឧត្តម **អ៊ុំ ពញ្ញា**	នាយកខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ	សមាជិក
៦. លោក **គាត សុធា**	ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ	សមាជិក
៧. លោក **អឿន ធារិទ្ធ**	ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍	សមាជិក
៨. កញ្ញា **ស៊ឹម ខលក្សណ៍**	សមាជិកខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ	សមាជិក
៩. លោក **គាង ឆាយហៀង**	ប្រធានការិយាល័យ នៃក្រសួងអភិវឌ្ឍន៍ជនបទ	លេខាធិការ

ប្រការ ២.-

ក្រុមការងារមានតួនាទីរៀបចំ សម្របសម្រួល និងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទតាមវិធីសាស្ត្រ «ចលនាភូមិថ្មី» មានតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការរៀបចំ និងសម្របសម្រួលការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទក្នុងលក្ខណៈជាប្រព័ន្ធ និងខ្សែចង្វាក់ប្រទាក់ក្រឡាគ្នា។

ក្រុមការងារនេះ មានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយអភិវឌ្ឍន៍ជនបទនៃព្រះរាជាណាចក្រកម្ពុជាតាមវិធីសាស្ត្រ «ចលនាភូមិថ្មី» ដោយសហការជាមួយអ្នកជំនាញនៃព្រះរាជាណាចក្រកម្ពុជា និងអ្នកជំនាញនៃសាធារណរដ្ឋកូរ៉េ ដើម្បីឱ្យមានសង្គតិភាពជាមួយគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា
- រៀបចំគម្រោង និងជ្រើសរើសទីតាំងភូមិសាស្ត្រសមស្របសម្រាប់ធ្វើការអនុវត្តសាកល្បងនូវគោលនយោបាយអភិវឌ្ឍន៍ជនបទ «ចលនាភូមិថ្មី»
- សម្របសម្រួលការអនុវត្តគម្រោងអភិវឌ្ឍន៍ស្របតាមគោលនយោបាយ ផែនការ និងទីតាំងភូមិសាស្ត្រដែលបានជ្រើសរើស
- ផ្សព្វផ្សាយព័ត៌មាន ដើម្បីជំរុញលើកទឹកចិត្តឱ្យប្រជាពលរដ្ឋស្វែងយល់អំពីទស្សនៈរបស់ «ចលនាភូមិថ្មី» និងចូលរួមអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទ តាមវិធីសាស្ត្រចលនាភូមិថ្មី
- កៀរគរថវិកា និងទាក់ទាញឱ្យមានការចូលរួមវិនិយោគ ពីវិស័យឯកជន និងដៃគូអភិវឌ្ឍន៍នៅក្នុងការអនុវត្តគម្រោង
- ធ្វើរបាយការណ៍ស្ដីពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងៗ ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

ប្រការ ៣.-

ក្រុមការងារត្រូវធ្វើការប្រជុំ តាមការអញ្ជើញរបស់ប្រធានក្រុមការងារ។

ប្រធានក្រុមការងារ អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល តំណាងដៃគូអភិវឌ្ឍន៍ និងអ្នកតំណាងពាក់ព័ន្ធចូលរួមប្រជុំតាមការចាំបាច់។

ប្រការ ៤.-

ក្រុមការងារប្រើប្រាស់ត្រារបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការចាត់ចែងការងាររបស់ខ្លួន។

ប្រការ ៥.-

សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភាឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៦
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com